








# ការឃ្លាំមើលមូលនិធិបន្សាំ និងផែនការបន្សាំជាតិ

## សន្និធានភាព

កម្ពុជា ត្រូវបានចាត់ថ្នាក់ជាបន្តបន្ទាប់ក្នុងចំណោមប្រទេសងាយរងគ្រោះបំផុតដោយសារការប្រែប្រួលអាកាសធាតុ និងជាប្រទេសងាយរងគ្រោះទី៣បំផុត នៅអាស៊ី។[១] នេះដោយសារកម្ពុជាបានរងការជន់លិចជាញឹកញាប់ និងការធ្លាក់ភ្លៀងដែលមិនអាចព្យាករណ៍បាន ក៏ដូចជាព្យុះត្រូពិក និងការឡើងកំពស់ទឹកសមុទ្រ និងមានសមត្ថភាពបន្សាំកម្រិតទាប។[២] ការវាយតម្លៃភាពងាយរងគ្រោះថ្មីៗនេះបានរកឃើញថា ឃុំចំនួន17,2% ងាយរងគ្រោះ"ជាខ្លាំង" និង 31,5% ងាយរងគ្រោះ"បង្គួរ" ដោយសារមុខសញ្ញានៃការប្រែប្រួលអាកាសធាតុជាច្រើនពោលគឺ ទឹកជំនន់ ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត[៣]។ ក្រោមក្របខ័ណ្ឌអនុសញ្ញា UNFCCC មានមូលនិធិពិភពលោកដូចជា មូលនិធិបរិស្ថានពិភពលោក មូលនិធិវិនិយោគអាកាសធាតុ (CIF) មូលនិធិបន្សាំ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុពិភពលោក(GCCA) មូលនិធិអាកាសធាតុបៃតង។ យន្តការមូលនិធិទាំងនោះត្រូវបានបង្កើតឡើងក្នុងគោលដៅ និងតាមវិធីខុសៗគ្នា ដើម្បីជួយប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាកម្ពុជា។

## គោលដៅនៃការស្រាវជ្រាវ

- វិភាគគោលនយោបាយជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ស្វែងយល់ពីការអនុវត្តគោលនយោបាយតាមមូលដ្ឋាននៅកម្ពុជា ទាក់ទងនឹងផែនការបន្សាំនៅថ្នាក់ជាតិរបស់កម្ពុជា
- អង្កេតជានទំនាក់ទំនងរវាងភ្នាក់ងារក្នុងការងារបន្សាំតាមមូលដ្ឋាននៅកម្ពុជា អនុវត្តដោយក្រសួងបរិស្ថាននិងស្ថាប័នដទៃទៀត
- ចងក្រងជាឯកសារនៃការអនុវត្តល្អៗ នៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់តំបន់ការពារធម្មជាតិនៅបឹងពែរ និង ករណីសិក្សាជាមួយគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុនៃ ADB។

## វិធីសាស្ត្រ

ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីចម្រុះ ទាំងទិន្នន័យបរិមាណនិងគុណភាព ដែលប្រមូលបានពីការសិក្សាលើឯកសារមានស្រាប់ ការសម្ភាសបុគ្គលសំខាន់ៗ និងករណីសិក្សានានា។

☞ **ការសិក្សាឯកសារមានស្រាប់៖** ការសិក្សាឯកសារមានស្រាប់នានាបានធ្វើឡើងដើម្បីពិនិត្យមើលលំហូរហិរញ្ញប្បទានប្រែប្រួលអាកាសធាតុពិភពលោក និន្នាការហិរញ្ញវត្ថុអាកាសធាតុដែលផ្តល់មកតំបន់អាស៊ី និងប៉ាស៊ីហ្វិក គោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាអំពីការប្រែប្រួលអាកាសធាតុ ការសិក្សាតាមមូលដ្ឋាន ថ្នាក់តំបន់ និងអន្តរជាតិដែលទាក់ទងនឹងហិរញ្ញប្បទានអាកាសធាតុ ឯកសារគម្រោង កម្រងទិន្នន័យអនឡាញ និងវេបសាយនានា។

☞ **ការសម្ភាសបុគ្គលសំខាន់ៗ៖** អ្នកពាក់ព័ន្ធនានាមកពីក្រសួង (នាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC), NCDDS, ម្ចាស់ជំនួយ (ADB, UNDP, SIDA, EU និង JICA), NGOs, SPCR, អាជ្ញាធរមូលដ្ឋាន អ្នកជំនាញការនិងអ្នកទទួលផលត្រូវបានសម្ភាស ដើម្បីផ្ទៀងផ្ទាត់ និងបំពេញព័ត៌មានបន្ថែមលើលទ្ធផលពីការសិក្សាឯកសារដែលមានស្រាប់។

☞ **ករណីសិក្សានានា៖** ករណីសិក្សាគម្រោងប្រែប្រួលអាកាសធាតុដែលទទួលមូលនិធិគាំទ្រពីម្ចាស់ជំនួយខុសៗគ្នា ត្រូវបានជ្រើសរើសសម្រាប់ការវិភាគជាបន្ថែម។ គោលដៅនៃករណីសិក្សាទាំងនោះគឺរកមើលជោគជ័យ និងការប្រឈមលើការអនុវត្តគម្រោងបន្សាំ។ ក្នុងករណីសិក្សានីមួយៗ អ្នកស្រាវជ្រាវបានធ្វើទស្សនកិច្ចតាមទីតាំងគម្រោង សម្ភាស និងពិគ្រោះ

[១] ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុកម្ពុជា, NCSD, August 2015.
[២] ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុកម្ពុជា (សេចក្តីព្រាង 2014)
[៣] ក្របខ័ណ្ឌជាតិតាមដាននិងវាយតម្លៃការប្រែប្រួលអាកាសធាតុកម្ពុជា, NCSD, April 2016.

យោបល់មួយចំនួនជាមួយអ្នកទទួលផល និងគម្រោង។

☞ **សិក្ខាសាលាពិគ្រោះយោបល់៖** របកគំហើញបឋមត្រូវបានបង្ហាញជូនអ្នកពាក់ព័ន្ធខុសៗគ្នា ជាអាទិ៍ ក្រសួងពាក់ព័ន្ធនៃរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារអេ.ស.ប ធនាគារពិភពលោក បណ្តាញ NGOs សហគមន៍មូលដ្ឋាន ក្នុងចំណោមអ្នកចូលរួម 71នាក់ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មាន និងផ្តល់ធាតុចូលបន្ថែមទៅក្នុងរបាយការណ៍នោះ។

## របកគំហើញសំខាន់ៗ

មានមូលនិធិពិភពលោក ដូចជាមូលនិធិបរិស្ថានពិភពលោក មូលនិធិវិនិយោគអាកាសធាតុ(CIF) មូលនិធិបន្សាំ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុពិភពលោក(GCCA) មូលនិធិអាកាសធាតុបៃតង។ យន្តការមូលនិធិទាំងនេះត្រូវបានបង្កើតឡើងក្នុងគោលដៅនិងតាមវិធីខុសៗគ្នា ដើម្បីជួយប្រទេសអភិវឌ្ឍន៍តិចតួចនិងប្រទេសកំពុងអភិវឌ្ឍន៍ដូចជា កម្ពុជា។

## យន្តការហិរញ្ញវត្ថុអាកាសធាតុ

និម្មាបនកម្មហិរញ្ញវត្ថុអាកាសធាតុពិភពលោកមានលក្ខណៈស្មុគស្មាញ៖ ហិរញ្ញវត្ថុត្រូវបញ្ជូនតាមរយៈមូលនិធិ ពហុភាគី ដូចជា មូលនិធិបរិស្ថានពិភពលោក និងមូលនិធិវិនិយោគអាកាសធាតុ ក៏ដូចជា តាមរយៈយន្តការទ្វេភាគីកាន់តែច្រើនឡើងផងដែរ។ លើសពីនេះ ប្រទេសអ្នកទទួលដែលមានចំនួនកាន់តែច្រើនឡើង បានបង្កើតមូលនិធិប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ ដែលទទួលមូលនិធិពីប្រទេសជឿនលឿនជាច្រើន នៅក្នុងកិច្ចប្រឹងប្រែងដើម្បីសម្របសម្រួលនិងបន្សីចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយជាមួយអាទិភាពជាតិ។

## មូលនិធិប្រែប្រួលអាកាសធាតុសម្រាប់ការបន្សាំនិងការកាត់បន្ថយនៅលើពិភពលោក

ប្រទេសទាំងអស់លើពិភពលោក ជាពិសេស ប្រទេសអភិវឌ្ឍន៍តិចតួច និងងាយរងគ្រោះ បាននិងកំពុងរងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុរួចមកហើយ ដោយសារតែការបំភាយឧស្ម័នផ្ទះកញ្ចក់ពីអតីតកាល និងបច្ចុប្បន្នកាល។ ហិរញ្ញវត្ថុនេះចាំបាច់ណាស់សម្រាប់គាំទ្រដល់សកម្មភាពនានាដែលឆ្លើយតបនឹងផលប៉ះពាល់ ផែនការ និងគោលនយោបាយរបស់រដ្ឋាភិបាល ដូចជា ការជន់លិច ព្យុះស៊ីក្លូន សំណឹកឆ្នេរសមុទ្រ គ្រោះរាំងស្ងួត និងកំណើនភាពមិនទៀងទាត់នៃការធ្លាក់ភ្លៀង។

☞ **សម្រាប់ផ្នែកបន្សាំ៖** ចក្រភពអង់គ្លេស តាមរយៈមូលនិធិអាកាសធាតុអន្តរជាតិ ស.រ.អា ស៊ុយអែដ និងកាណាដា ដែលតំណាងឲ្យ 69%នៃទឹកប្រាក់ 3 ពាន់លានដុល្លាអាមេរិក ដែលបានសន្យាសម្រាប់មូលនិធិបន្សាំមកទល់ពេលនេះ ដោយក្នុងចំណោមតួលេខនេះ ទឹកប្រាក់ 2,72 ពាន់លានដុល្លាអាមេរិក ត្រូវបានដាក់តំកល់រួចមកហើយ។ 79% នៃហិរញ្ញវត្ថុដែលបានតំកល់នេះ ត្រូវបានអនុម័តសម្រាប់គាំទ្រគម្រោង និងកម្មវិធីនានា។ ប្រទេសដែលទទួលបានហិរញ្ញវត្ថុបន្សាំច្រើនជាងគេចំនួនម្ភៃ (ក្នុងចំណោម 114ប្រទេស) បានទទួល 54% នៃទឹកប្រាក់សរុបដែលបានអនុម័ត មានជាអាទិ៍ បង់ក្លាដែស ម៉ូហ្សំប៊ិក នីហ្សេរ៉េនេប៉ាល់ ហ្សំប៊ី ក្នុងនោះប្រទេសនីមួយៗបានទទួលរវាង 94-190 លានដុល្លាអាមេរិក (ប្រទេសទាំងប្រាំក៏បានអនុវត្តកម្មវិធី PPCR ផងដែរ) ហើយប្រទេសដែលទទួលបានហិរញ្ញវត្ថុច្រើនជាងគេបន្ទាប់បានទទួលពី 55 ដល់ 90 លានដុល្លាក្នុងប្រទេសនីមួយៗ។




| មូលនិធិ | សន្យា (លានដុល្លាអាមេរិក) | បានតម្កល់ | បានអនុម័ត |
|---|---|---|---|
| កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) | 1,160.00 | 973.00 | 796.00 |
| ប្រទេសអភិវឌ្ឍន៍តិចតួច | 914.47 | 903.05 | 733.40 |
| ការបន្សាំសម្រាប់កម្មវិធីកសិកម្មខ្នាតតូច(ASAP) | 352.86 | 300.66 | 149.91 |
| មូលនិធិប្រែប្រួលអាកាសធាតុពិសេស (SCCF) | 347.30 | 336.07 | 253.50 |
| មូលនិធិបន្សាំ (AF) | 226.33 | 213.71 | 231.55 |

☞ សម្រាប់ផ្នែកកាត់បន្ថយៈ ស.រ.អា ជប៉ុន ចក្រភពអង់គ្លេស អាល្លឺម៉ង់ និងបារាំង សន្យាផ្តល់ដល់មូលនិធិទាំងប្រាំឲ្យបាន 77% នៃទឹកប្រាក់ 9 ពាន់លានដុល្លាអាមេរិក ដែលជាការប្តេជ្ញាសរុប។ 5,3ពាន់លានដុល្លា នៃចំនួនដែលប្រទេសទាំងនេះបានសន្យាត្រូវបានប្រទេសទាំងនេះដាក់តម្កល់នៅក្នុងមូលនិធិទាំងនេះរួចហើយ។ ទឹកប្រាក់ 5,8ពាន់លានដុល្លា ឬត្រូវជា 86%នៃចំនួនដែលម្ចាស់ជំនួយទាំងអស់បានតម្កល់ ត្រូវបានអនុម័តដើម្បីជួយគម្រោងនិងកម្មវិធីនានា។ ហិរញ្ញវត្ថុសម្រាប់ការកាត់បន្ថយត្រូវបានបែងចែកស្ទើរតែស្មើគ្នាក្នុងតំបន់កំពុងអភិវឌ្ឍន៍។

| មូលនិធិ | សន្យា (USD) | បានតម្កល់ | បានអនុម័ត |
|---|---|---|---|
| មូលនិធិបច្ចេកវិទ្យាស្អាត (CTF) | 5.242 | 4.599 | 3.840 |
| មូលនិធិគ្រឹះបរិស្ថានពិភពលោក (GEF 4) | 754 | 754 | 956 |
| មូលនិធិគ្រឹះបរិស្ថានពិភពលោក (GEF 5) | 1.350 | 777 | 799 |
| មូលនិធិប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញពិភពលោក (GEEREF) | 170 | 164 | 89,07 |
| កម្មវិធីពង្រីកថាមពលកកើតឡើងវិញសម្រាប់ប្រទេសមានចំណូលទាប (SREP) | 521 | 506 | 135,99 |

## ផែនការនិងគោលនយោបាយរដ្ឋាភិបាល

រាជរដ្ឋាភិបាលកម្ពុជា បានត្រៀមខ្លួនសម្រាប់ការចាត់ចែងស្ថាប័នដើម្បី ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដូចជាបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានរៀបចំផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា 2014-2023 ហើយផែនការសកម្មភាពប្រែប្រួលអាកាសធាតុ(CCAPs) ចំនួន 15 ត្រូវបានអនុម័តដោយក្រសួងពាក់ព័ន្ធចំនួន 15។




## ក្របខ័ណ្ឌស្ថាប័នស្តីពីការប្រែប្រួលអាកាសធាតុ

នាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC) បានបង្កើតឡើងនៅឆ្នាំ 2009។ នាយកដ្ឋាននេះទទួលខុសត្រូវលើសកម្មភាពជាច្រើន ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងមាននាទីជាស្ថាប័នបង្គោលរបស់កម្ពុជាសម្រាប់ UNFCCC គណៈកម្មការអន្តររដ្ឋាភិបាលស្តីពី ការប្រែប្រួលអាកាសធាតុ (IPCC) និងពិធីសារក្យូតូ។ នាយកដ្ឋាននេះក៏សម្របសម្រួលក្រុមការងារអាកាសធាតុដែលទាក់ទងនឹងវិស័យ ឬ បញ្ហានានា ដូចជា ថាមពល ព្រៃឈើ សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ភាពងាយរងគ្រោះ និងការបន្សាំ។ល។ផងដែរ។

នៅខែកក្កដា ឆ្នាំ ២០១២, ក្រសួងបរិស្ថានត្រូវបានតែងតាំងជាស្ថាប័នជាតិ (DNA) ទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត (CDM)។ នាយកដ្ឋានប្រែប្រួលអាកាសធាតុដើរតួជាលេខាធិការដ្ឋាននៃ DNA។

ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុCCTTនឹងត្រូវជំនួសដោយក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ (CCTWG) ក្នុងឆ្នាំ2016 ដើម្បីធានាប្រសិទ្ធភាពនៃជំនួយបច្ចេកទេស និងធាតុចូលអំពីការប្រែប្រួលអាកាសធាតុសម្រាប់ NCSD។ CCTWG ផ្តល់ ការគាំទ្រដល់ក្រសួងពាក់ព័ន្ធសម្រាប់រៀបចំ CCAPs តាមវិស័យ។




## មូលនិធិអាកាសធាតុនៅកម្ពុជា

ការចំណាយលើការប្រែប្រួលអាកាសធាតុនៅកម្ពុជា បានកើនឡើងជាបណ្តើរៗ ក្នុងអំឡុងពេលនៃរបាយការណ៍នេះពី 367 ពាន់លានរៀល នៅឆ្នាំ 2009 ដល់ 847 ពាន់លានរៀល នៅឆ្នាំ 2014។ សមាមាត្រនៃការចំណាយលើអាកាសធាតុធៀប

នឹងផ.ស.ស ក៏បានកើនជារួមផងដែរពី 0,9%នៃផ.ស.ស នៅឆ្នាំ2009 ដល់ 1,3%នៃផ.ស.ស នៅឆ្នាំ 2014 ដោយមានតួលេខទាបនៅឆ្នាំ 2011 (0,8% នៃផ.ស.ស)។ ឆ្នាំ2009 និង 2010 មានការចំណាយខ្ពស់លើការស្តារស្ថានភាពពីគ្រោះមហន្តរាយដោយសារព្យុះកេតសាណា និងទឹកជំនន់នៅចុងឆ្នាំ 2009។

នៅឆ្នាំ2014 មួយភាគបីនៃការចំណាយសាធារណៈទាក់ទងទាំងស្រុង ឬមួយផ្នែកទៅនឹងការប្រែប្រួលអាកាសធាតុ (កើនពី 28,9% នៅឆ្នាំ 2009)។ នៅពេលគិតបញ្ចូលមេគុណនៃការពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការចំណាយនេះ ការប្រែប្រួលអាកាសធាតុមាន4,1% នៃការចំណាយសាធារណៈ (កើនពី 3,3% នៅឆ្នាំ 2009)។

ចំនួននេះបានពីប្រភពក្នុងស្រុកចំណែក41%ជាមូលនិធិពីក្រៅប្រទេស (ម្ចាស់ជំនួយ)។




## គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយ

| | ២០១២ (លានUSD) | ២០១៣ (លាន USD) | ២០១៤ លានUSD) |
|---|---|---|---|
| ការកាត់បន្ថយ | 6,19 | 7,88 | 4,12 |
| ការបន្សាំ | 116,11 | 152,15 | 207,69 |

## ការបន្សាំនឹងការប្រែប្រួលអាកាសធាតុគិតតាមវិស័យ




## ចំណងទាក់ទងជាមួយផែនការសកម្មភាពជាតិ

### ការបន្ស៊ីគ្នារវាង CCAPs និង CCCSP

| គោលដៅយុទ្ធសាស្ត្រនៃ CCCSP | CCAP (ចំនួនសកម្មភាព) | CCAP (%) |
|---|---|---|
| 1. លើកកំពស់ភាពធន់នឹងអាកាសធាតុតាមរយៈការកែលម្អសន្តិសុខស្បៀង ទឹក និងថាមពល | 37 | 14% |
| 2. កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ និងយេនឌ័រនិងហានិភ័យសុខភាពចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | 51 | 20% |
| 3. ធានាភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរសមុទ្រ តំបន់ភ្នំ។ល។) ជីវចម្រុះ តំបន់ការពារធម្មជាតិ និងទីតាំងបេតិកភណ្ឌវប្បធម៌ | 27 | 10% |
| 4. លើកកំពស់ការរៀបចំផែនការ និងបច្ចេកវិទ្យាកាបូនទាបដើម្បីទ្រទ្រង់ការអភិវឌ្ឍដោយចីរភាព | 56 | 22% |
| 5. កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | 68 | 26% |
| 6. លើកកំពស់កិច្ចគាំពារសង្គមតាមបែបបន្សាំ និងវិធីសាស្ត្រចូលរួមក្នុងការកាត់បន្ថយការបាត់បង់និងការខូចខាតដោយសារការប្រែប្រួលអាកាសធាតុ | 8 | 3% |
| 7. ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌសម្របសម្រួលសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | 11 | 4% |
| 8. ពង្រឹងកិច្ចសហការ និងការចូលរួមសកម្មក្នុងដំណើរការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់និងពិភពលោក | 2 | 1% |
| **សរុប** | 260 | 100% |

## ការអនុវត្ត CCAPs និងភាពខ្វះចន្លោះ

| ល.រ | ក្រសួង | ថ្លៃចំណាយ (លានUSD) | ហិរញ្ញវត្ថុទទួលបាន (លានUSD) | គម្លាតជា (លានUSD ) | គម្លាតជា % |
|---|---|---|---|---|---|
| 1 | MAFF | 187,55 | 54,69 | 132,86 | 70.84 |
| 2 | MIH | 11 | 11,70 | -0,70 | -6.39 |
| 3 | MLMUPC | 9,12 | 0,25 | 8,87 | 97.26 |
| 4 | MME | 5,02 | 0,25 | 4,77 | 95.02 |
| 5 | MOE | 27,67 | 19,29 | 8,38 | 30.28 |
| 6 | MOEYS | 10,6 | 0,35 | 10,25 | 97.70 |
| 7 | MOH | 46,8 | 0,40 | 46,4 | 99.15 |
| 8 | MOINFO | 4,33 | 0,13 | 4,205 | 97.12 |
| 9 | MOT | 3,4 | 0,13 | 3,28 | 96.79 |
| 10 | MoWA | 3,62 | 0,10 | 3,52 | 97.24 |
| 11 | MoWRAM | 272,5 | 75,20 | 197,3 | 72.40 |
| 12 | MPTC (មិនទាន់អនុវត្ត) | 4,61 | 0,00 | 4,61 | 100 |
| 13 | MPWT | 210,98 | 8,21 | 202,775 | 96.11 |
| 14 | MRD | 56,53 | 74,33 | -17,8 | -31.00 |
| 15 | NCDM | 11,75 | 0,10 | 11,65 | 99.15 |
| **សរុប** | | 865,47 | 245,12 | 620,37 | 71,68 |

## ការគៀងគរធនធានសម្រាប់សកម្មភាពបន្សុំា

យុទ្ធសាស្ត្រក្នុងការគៀងគរធនធានបន្ថែម ត្រូវផ្តោតលើប្រភពថវិកាមួយចំនួន ដែលថវិកាក្នុងស្រុកត្រូវបានរំពឹងថានឹងមានឆន្ទៈនយោបាយ ការជម្រុញនីតិវិធីរៀបចំផែនការ និងថវិកាបញ្ជ្រាបការប្រែប្រួលអាកាសធាតុ រួមទាំងកម្មវិធីវិនិយោគសាធារណៈ។ យោងតាមថវិការប្រែប្រួល អាកាសធាតុអន្តរជាតិ ក.ជ.អ.ច. ជាមួយការចូលរួមរបស់ GIZ បានចាត់អទិភាពសកម្មភាពអាទិភាពរបស់វិស័យCCAPsព្រមទាំងការកំនត់ថវិកាអាទិភាពខ្ពស់ ទាំងនេះជាការអភិវឌ្ឍផ្សេងៗ របស់គម្រោងសំណើថវិកា ដែលនឹងត្រូវបានបង្ហាញទៅដៃគូម្ចាស់ជំនួយចម្រុះ។ពីនេះទៀត ឧបករណ៍ក្នុងការសម្រាំង ត្រូវបានបង្កើតក្នុងការកែតម្រូវ សម្រាំង ចាត់អាទិភាពសកម្មភាព CCAP សម្រាប់គោលបំណងផ្សេងៗនៅអនាគត។ ធនធានចម្បងរបស់ហិរញ្ញវត្ថុបន្សុំាអន្តរជាតិ គឺជាមូលនិធិអាកាសធាតុបៃតង(GCF)។កម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលត្រៀមរួចជាស្រេច ដើម្បីទទួលបានថវិកាបន្សុំាពីGCFតាមរយៈពហុដៃគូ និងការទទួលបានដោយផ្ទាល់ដូចជា AF, SPCR, IFAD/ASPIRE, GEF..etc.។ វាមានលទ្ធភាពក្នុងការពង្រីកការស្វែងរកមូលនិធិបន្សុំាបន្ថែមទៀតតាមរយៈជំនួយទ្វេភាគី និងប្រភពថវិការផ្សេងទៀតដូចជាមូលនិធិ យន្តការមូលនិធិបន្សុំាភាពជាដៃគូរដ្ឋ និងឯកជន ការបង់ថ្លៃសេវាកម្មវិស័យបរិស្ថាន ដូចជា រ៉េតបូក និងយន្តការមូលនិធិផ្សេងៗទៀត។

យុទ្ធសាស្ត្រក្នុងការគៀរគរមូលនិធិផ្សេងៗទៀត វិធីសាស្ត្រក្នុងការចាប់ផ្តើមសាកល្បងជាចំណុច ដែលមានការចូលរួមរបស់អ្នកពាក់ព័ន្ធសំខាន់ៗដូចជា រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានឧត្តមសិក្សា និងសហគមន៍។ ភាគីពាក់ព័ន្ធសំខាន់ៗបានបង្កើតឡើង ដែលជាបទពិសោធន៍ នៅក្នុការរៀបចំផែនការ និងការអនុវត្តសកម្មភាពជាប់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ គួរត្រូវបានពង្រីក និងពង្រឹង។

## អនុសាសន៍

1. ពង្រឹងក្រសួងបរិស្ថាននិងក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព ដើម្បីសម្របសម្រួលបានប្រសើរជាងមុននូវសកម្មភាពដែលទាក់ទងនឹងហិរញ្ញប្បទានសម្រាប់ផែនការសកម្មភាពជាតិ ដែលរួមទាំងសកម្មភាពទាក់ទងនឹងការទទួលបានមូលនិធិអាកាសធាតុបៃតង (GCF);
2. ពង្រឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើសមត្ថភាពវាយតម្លៃ និងតាមដានផលប៉ះពាល់នៃអាកាសធាតុមកលើសេដ្ឋកិច្ច និងប្រើប្រាស់សមត្ថភាពនេះក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាពិសេស តាមរយៈដំណើរការលើកថវិកាជាតិ
3. បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងថវិកាជាតិ
4. កែសម្រួលកម្រងទិន្នន័យ ODA ឲ្យស្របតាមមូលនិធិបន្សុំា
5. ភ្នាក់ងារអន្តរវិស័យទាំងអស់ (រដ្ឋាភិបាល DPs និងNGOs) គួរមានយន្តការសម្របសម្រួលគ្នា ពាក់ព័ន្ធនឹងការអនុវត្តគម្រោងបន្សុំា
6. ផ្តល់ហិរញ្ញវត្ថុអាកាសធាតុថ្មីនិងបន្ថែម ស្របជាមួយការប្តេជ្ញានៅក្រោមUNFCCCប៉ុន្តែធានាផងដែរថាគម្រោងODA តាមរបៀបពីមុនមក មានភាព"ឆ្លាតចំពោះអាកាសធាតុ"។
7. ចំពោះគម្រោងដែលបានកំណត់ថាពាក់ព័ន្ធ ត្រូវធានាថាមានការទទួលបានធាតុចូលខាងបច្ចេកទេសនៅក្នុងដំណាក់កាលរៀបចំពីNCSDនិង/ឬក្រុមការងារអាកាសធាតុនៅក្នុង

ក្រសួងពាក់ព័ន្ធ ដែលរួមទាំង ស្តង់ដារធន់នឹងអាកាសធាតុដែលអាចប្រើការបាន ឬ វិធានការចាំបាច់ដទៃទៀត និងដាក់បញ្ចូលថ្លៃចំណាយនិងធាតុចូល ដែលពាក់ព័ន្ធទៅក្នុងថវិកាគម្រោង។

8. នៅពេលផ្តល់ការគាំទ្រថវិកាតាមវិស័យ ឬ ទូទៅត្រូវដាក់បញ្ចូលការប្រែប្រួលកអាកាសធាតុនៅក្នុងក្របខ័ណ្ឌលទ្ធផល (ស្របជាមួយCCCSP និងក្របខ័ណ្ឌM&E របស់ជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ) និងផ្តល់ហិរញ្ញវត្ថុអាកាសធាតុដើម្បីជួយគម្រោងទាំងនេះ។
9. បង្កើនកម្រិតហិរញ្ញវត្ថុដែលមាននៅថ្នាក់មូលដ្ឋាន តាមរយៈ CSF, DMF និង SNIF ដោយធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការ និងនីតិវិធីលើកផែនការសម្រាប់មូលនិធិទាំងនេះ។
10. ក្នុងករណីពាក់ព័ន្ធត្រូវដាក់បញ្ចូលការគាំទ្រដល់អន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុទាំងនៅកម្រិតបុគ្គល(ការអភិវឌ្ឍជំនាញ) និងនៅកម្រិតស្ថាប័ន(និយមន័យស្តង់ដារដែលអាចអនុវត្តបានការស្រាវជ្រាវ និងអភិវឌ្ឍន៍)។

## ការសន្និដ្ឋាន

☞ កម្ពុជា កំពុងឈានទៅមុខលើការត្រៀមលក្ខណៈសម្រាប់ការប្រែប្រួលអាកាសធាតុ ដូចជា ការចាត់ចែងស្ថាប័ន ការប្តេជ្ញាខាងគោលនយោបាយ ការអភិវឌ្ឍនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលរួមទាំង CCCSP, CCAPs តាមវិស័យ និងគោលការណ៍ណែនាំសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅថ្នាក់ក្រោមជាតិ។

☞ សារៈសំខាន់នៃកិច្ចប្រឹងប្រែងលើការបន្សាំត្រូវបានពង្រីកក្នុងប្រទេស ហើយទឹកប្រាក់ខ្លះត្រូវបានចំណាយសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសសម្រាប់ការបន្សាំ សូម្បីពីដៃគូអភិវឌ្ឍន៍ និងពីថវិកាជាតិក៏ដោយ។ ដំណើរការរៀបចំNAPនិងផែនទីបង្ហាញផ្លូវត្រូវបានដាក់ឲ្យអនុវត្តដើម្បីរកប្រភព សម្រាប់រៀបចំឯកសារ CCAPs ពីគ្រប់វិស័យនៃរដ្ឋាភិបាល។

☞ ការកសាងសមត្ថភាព ការគ្រប់គ្រងបច្ចេកទេស ការអង្កេតដាន ODA និងការកៀរគរមូលនិធិ នៅតែត្រូវការរៀបចំរួមទាំងមន្ត្រីស្ថាប័នរដ្ឋាភិបាលដៃគូរអភិវឌ្ឍន៍និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

**គាំទ្រឧបត្ថម្ភដោយៈ**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

ADAPTATION FUND NGO NETWORK

GERMANWATCH

DCA actalliance

Southern Voices on Climate Change

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ-៣ កម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែលៈ **ngoforum@ngoforum.org.kh**
គេហទំព័រៈ **www.ngoforum.org.kh**